ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០១៧

**សេចក្តីផ្តើម** :

នៅក្នុងខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា<br>- បានចូលរួមប្រជុំជាមួយគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា ដើម្បីពិនិត្យលើសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា<br>- បានចូលរួមក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី៥ នៃរដ្ឋសភា ដើម្បីឆ្លើយបំភ្លឺលើសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា<br>- ប្រជុំពិនិត្យ និងសិក្សាលើសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា<br>- ប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងនៃការកំណត់ចំណាត់ថ្នាក់មុខងារ ស្របតាមចំណាត់ថ្នាក់មុខងាររាជរដ្ឋាភិបាល(COFOG)<br>- ប្រជុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងសេចក្តីសម្រេចរួមស្តីពី គោលការណ៍ និងលក្ខខណ្ឌនៃការធ្វើសមាហរណកម្មក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ<br>- ថតចម្លងឯកសារបានចំនួន៣៩៧ច្បាប់ និង |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | រៀបចំចងក្រងធ្វើជាសៀវភៅចំនួន៣០ក្បាល អស់ក្រដាសចំនួន១៥,៨៤៣សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញចំនួន ១០នាក់ ស្មើនឹង០២លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗចំនួន៦៧នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់ ពីរដ្ឋសភា និងរាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន៤៣ច្បាប់<br>- ធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា និងបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងបន្តសិក្សាស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន០៤ច្បាប់<br>- បានសិក្សាស្រាវជ្រាវ និងសង្ខេបព័ត៌មានប្រចាំថ្ងៃអំពីសភាប្រទេសនានា<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៣លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន១៦លើក<br>- ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង |

| | |
|---|---|
| | សេចក្ដីប្រកាសព័ត៌មានចំនួន០៤លើក<br>- បានបញ្ចូលឯកសារច្បាប់របស់ព្រឹទ្ធសភា នីតិកាលទី១ និងទី២ ក្នុងគេហទំព័រ E-library ព្រឹទ្ធសភា ។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សា ឃុំ ដើម្បីឈ្វេងយល់អំពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នៅខេត្តកំពង់ស្ពឺ<br>+ អញ្ជើញចុះសិក្សាឈ្វេងយល់ពីកត្តាសំខាន់ៗដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនៅជុំវិញបឹងទន្លេសាប ។ | - ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន០៤នាក់ ស្មើនឹង០១ច្បាប់ ។ |

## ៣.មុខងារតំណាង :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល គម្រប់ព្រះជន្មាយុ៨១ យាងចូល៨២ ព្រះវស្សា នៅព្រះបរមរាជវាំង<br>+ អញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍អបអរសាទរខួបលើកទី៥នៃទំនាក់ទំនងការទូតកម្ពុជា វៀតណាម | - រៀបចំបែបបទ ផ្ដល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីក្នុងពិធីផ្សេងការផ្សេងៗសរុបចំនួន៣៣៩លើក<br>- បានផ្ដល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានឈ្វេងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងកម្មវិធីផ្សេងៗ<br>- បានសហការរៀបចំ និងចាត់ចែងពិធីគោរព |

| | |
|---|---|
| នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា<br>+ អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបគម្រប់ ២ឆ្នាំ និងគម្រប់៨ឆ្នាំ ដើម្បីឧទ្ទិសមហាកុសលជូនចំពោះវិញ្ញាណក្ខន្ធ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** និងលោកជំទាវ និងចូលរួមពិធីបុណ្យខួបគម្រប់១០០ថ្ងៃ **សម្តេចវិបុលបញ្ញា សុខ អាន** ព្រមទាំងគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **សឿ ភូ** ជាភរិយារបស់ឯកឧត្តម ជុំ វង់ សមាជិកគណៈកម្មការទី៦ ព្រឹទ្ធសភា នៅរាជធានីភ្នំពេញ ខេត្តព្រៃវែង និងខេត្តកំពង់ស្ពឺ<br>+ អញ្ជើញចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខេត្ត អាជ្ញាធរ ក្រុមប្រឹក្សាឃុំ មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅខេត្តកំពត និងខេត្តកណ្តាល ព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភដល់សិល្បករ សិល្បការិនីចំនួន ៣០០នាក់ នៅមជ្ឈមណ្ឌលកោះពេជ្រ<br>+ អញ្ជើញដឹកនាំប្រជុំ ដើម្បីត្រៀមចូលរួមកិច្ចប្រជុំស្តីពី ការលើកកម្ពស់កិច្ចសហប្រតិបត្តិការសភានៃតំបន់អាស៊ី អឺរ៉ុប និងចូលរួមប្រជុំការងារគណៈកម្មាធិការប្រតិបត្តិ ដើម្បីប្រកាសទទួលស្គាល់អនុប្រធានសមាគមមិត្តភាពកម្ពុជា ចិន និងបញ្ហាផ្សេងៗមួយចំនួនទៀត<br>- បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី ទទួលលិខិត | វិញ្ញាណក្ខន្ធសពចំនួន០២លើក<br>- បានសហការរៀបចំពិធីបុណ្យខួបគម្រប់២ឆ្នាំ និង៨ឆ្នាំឧទ្ទិសកុសលជូន**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** និងលោកជំទាវ<br>- ផ្ញើលិខិតថ្វាយព្រះពរជូន**សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ** គម្រប់៨១ យាងចូល៨២ព្រះវស្សា<br>- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់<br>- ផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២០០នាក់ ស្មើនឹង៤៤ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០២នាក់ ស្មើនឹង០២ច្បាប់<br>- ថតចម្លងឯកសារចំនួន១៨២ច្បាប់ អស់ក្រដាសចំនួន១,៩០៤សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្តាខេត្ត ក្រុង រាជធានីទាំង៨ភូមិភាគចំនួន៣៧នាក់ ស្មើនឹង ១៦លើក<br>- ទទួលលិខិតចូលចំនួន៧៧៣ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៤១ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗសរុបចំនួន៣៨លើក |

| | |
|---|---|
| ឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០១ករណី ទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០៤ករណី និងកំពុងពិនិត្យសិក្សាចំនួន០៤ករណី ព្រមទាំងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៥ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុងរាជធានីទូទាំងប្រទេសចំនួន៣៣៩លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព ក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៤៦លើក ។ | - បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងពិធីផ្សេងៗចំនួន១៥នាក់ ស្មើនឹង០១លើក<br>- ផ្តល់រូបថតចំនួន៤៦២សន្លឹក និងអត្ថបទសារព័ត៌មានចំនួន២៣អត្ថបទ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៣៥នាក់ ធ្វើប័ណ្ណសមាជិកចំនួន០៣នាក់ ខ្ចីសៀវភៅចំនួន៧២ក្បាល និងសងវិញចំនួន៧០ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន០២លើករបស់គណៈប្រតិភូឥណ្ឌា និងនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញសរុបចំនួន១៦នាក់<br>- ទទួលឯកសារសៀវភៅពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រឹត្តិបត្រទស្សនាវដ្តីចំនួន១២៥ក្បាល និងកាសែតចំនួន១៩០ច្បាប់<br>- ថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន៤៦លើក<br>- ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៤៩លើក ។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឲ្យប្រធានCDI- | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជន |

| | |
|---|---|
| International និងជាអតីតប្រធានាធិបតីកូឡុំប៊ី និងក្រុមអ្នកអង្កេតការណ៍បោះឆ្នោតអន្តរជាតិ ចំនួន២៩រូប ចូលជួបសម្តែងការគួរសម និងសវនាការ<br>- សមាជិក សមាជិកាព្រឹទ្ធសភាបានអនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតឡាវ គណៈប្រតិភូប៉ូឡូញ គណៈប្រតិភូជប៉ុន នាយកប្រតិបត្តិនៃវិទ្យាស្ថានសន្ទនាមេគង្គ(MDI) និងសហការី និងស្ថានទូតសិង្ហបុរី ចូលជួបពិភាក្សាការងារ សម្តែងការគួរសម និងសវនាការ<br>- ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី ការលើកកម្ពស់កិច្ចសហប្រតិបត្តិការសភានៃតំបន់អាស៊ីអឺរ៉ុប នៅសាធារណរដ្ឋកូរ៉េ និងទស្សនកិច្ចសិក្សាឈ្វេងយល់នូវបច្ចេកវិទ្យាទំនើបៗ និងចំណេះដឹងទាក់ទងនឹងវិស័យចិញ្ចឹមសត្វ ការកែច្នៃចំណីអាហារ ការធ្វើទំនើបកម្មកសិដ្ឋាន និងការអភិវឌ្ឍជនបទ នៅប្រទេសហុងគ្រី និងសាធារណរដ្ឋបារាំង ។ | នយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- ធ្វើពិព័រណ៍រូបភាព បដា ពាក្យស្លោក និងធ្វើហ្វុងអក្សរក្នុងពិធីផ្សេងៗចំនួន០៥លើក<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ អន្តរជាតិ មកបំពេញទស្សនចំនួន០៧លើក<br>- រៀបចំសម្អាត តុបតែងសាល បម្រើ និងផ្តល់សេវាកេសជ្ជៈក្នុងពិធីផ្សេងៗចំនួន០៣លើក ស្មើនឹង៣៥នាក់<br>- ថតចម្លងឯកសារចំនួន១៤៦ច្បាប់ អស់ក្រដាសចំនួន៣២៤សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង រាជធានីទាំង៨ភូមិភាគចំនួន៥២នាក់ ស្មើនឹង១១លើក<br>- ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត ធ្វើសំណើ និងលិខិតឆ្លើយតបទៅក្រសួងផ្សេងៗចំនួន១៦លើក<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១២នាក់ ស្មើនឹង០៤ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងឧបត្ថម្ភមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ថ្លៃចំណាយផ្សេងៗចំនួន០៦លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ដោយប្រើប្រាស់កម្លាំងសរុបចំនួន៧៩នាក់ |

| | |
|---|---|
| | ស្មើនឹង០៧លើក<br>- អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយទីប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកសេវាស្រាវជ្រាវព្រឹទ្ធសភាឥណ្ឌា និងលេខាទូតជប៉ុន<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង សមាគមបេសកកម្មកម្មសិក្សាអាស៊ី ក្រសួង ស្ថាប័ន និងបណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅព្រឹត្តបត្រ និងដំណើរទស្សនកិច្ច សិក្ខាសាលាបំពេញបេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ ។ |

## ៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៦៧៩ច្បាប់ ។<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន១៨ច្បាប់<br>- ប្រជុំពិនិត្យ និងវាយតម្លៃបេក្ខជនត្រៀមតាំងស៊ប់មុខតំណែងគ្រប់គ្រង និងការប្រឡងធ្វើតេស្ត<br>- ប្រជុំគណៈកម្មការគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០១៦<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំអន្តរគណៈកម្មការចំពោះកិច្ច ដើម្បីពិនិត្យ |

| | |
|---|---|
| | សេចក្តីព្រាងសេចក្តីកែសម្រួល សេចក្តីព្រាងសេចក្តីសម្រេចរួមស្តីពី ការធ្វើសមាហរណកម្មក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ<br>- រៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី ភារកិច្ចអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស :<br>- កិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង និងក្រៅប្រទេស សរុបចំនួន១០វគ្គ មានសិក្ខាកាមចូលរួមចំនួន១៣០នាក់<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) បើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសសម្រាប់មន្ត្រីសភា និងអនុវត្តកម្មវិធីកម្មសិក្សាពីនិស្សិតក្នុងប្រទេស និងក្រៅប្រទេស ។<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :<br>- ប្រជុំសិក្សាអំពីអង្គភាពថវិកាតាមកម្មវិធី និងសមិទ្ធកម្មកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ<br>- រៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (២០១៨-២០២០) និងគម្រោងថវិកាប្រចាំឆ្នាំ២០១៨ របស់ព្រឹទ្ធសភា<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែមិថុនាឆ្នាំ២០១៧ ផ្ញើជូនក្រសួងសេដ្ឋកិច្ច |

| | |
|---|---|
| | និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច ជួសជុលរថយន្ត និងសម្ភារៈឧបករណ៍បច្ចេកទេសផ្សេងៗ ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធ កែលម្អសោភ័ណ្ឌភាពក្នុងបរិវេណព្រឹទ្ធសភាចំនួន ៧៥លើក<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន១៦សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ អាហារសម្រន់ និងភេសជ្ជៈចំនួន២០សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន១៩លើក មានអ្នកចូលរួមចំនួន៥៦៩នាក់<br>- ផ្តល់សេវាថវិកាសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងទូទាត់ថ្លៃចំណាយផ្សេងចំនួន៨៧លើក<br>- ថតចម្លងឯកសារបានចំនួន២,០៨០ច្បាប់ អស់ក្រដាសចំនួន១៥,២០៥សន្លឹក ព្រមទាំងផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីភ្នំពេញចំនួន១២២នាក់ ស្មើនឹង៣៨លើក ។<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់:<br>- រៀបចំបែបបទសុំជំនួយពីសាធារណរដ្ឋប្រជា- |

| | |
|---|---|
| | មានិតចិន ដើម្បីសាងសង់សាលប្រជុំពេញអង្គថ្មី<br>- បានធ្វើបែបបទស្នើសុំជំនួយពីប្រទេសជាមិត្ត សម្រាប់នីតិកាលថ្មី ព្រឹទ្ធសភា<br>- សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី និងដំណើរការជួសជុលអគារមូលនិធិ<br>- ជួសជុល កែលម្អ ខាត់ លាប ឃ្លាំងដាក់សម្ភារៈ និងធ្វើកៅអី សម្រាប់ដាក់នៅសាលប្រជុំ ព្រមទាំងក្រាលកម្រាលព្រំថ្មីនៅក្នុងសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សាលសាឡុងធំ និងសាលរង់ចាំ<br>- សាងសង់បន្ទប់ការិយាល័យបន្ថែម និងបន្ទប់ទឹក នៅអគារមូលនិធិ និងសាលបណ្ណាល័យ<br>- រៀបចំសុំគោលការណ៍ ដើម្បីត្រៀមរៀបចំជួសជុល អគារសាលប្រជុំពេញអង្គចាស់<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា ឲ្យមានសោភ័ណ្ឌភាពល្អ<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម ប្តូរសោគុ ដៃទ្វារ សរុបចំនួន១២៩គ្រឿង<br>- បិទលេខកូដសម្ភារៈសារពើភ័ណ្ឌចំនួន១៧គ្រឿង<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន៥៤គ្រឿង ។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១៣៧ |

| | |
|---|---|
| | ចំណាស់ជើង ។<br>+ការងារផ្សេងៗ:<br>- បានរៀបចំ និងបញ្ចូលលេខកូដឯកសារសៀវភៅច្បាប់ សៀវភៅជំនាញផ្សេងៗ និងចុះបញ្ជីឯកសារ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ ជួសជុល និងផ្លាស់ប្តូរលេខកូដចាស់ៗសរុបចំនួន១,០៨២ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និង បញ្ចូលសៀវភៅតាម PMB E-Library បណ្តាញ Facebook សរុបចំនួន៤,៨០៣ក្បាល ។ |

**II.ទិសដៅការងារខែកក្កដា ឆ្នាំ២០១៧**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណ:កម្មាធិការអចិន្ត្រៃយ៍ និងប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៣

-ត្រៀមបោះពុម្ពអត្ថបទច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និង ពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌ សមាជិកព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងថ្មី ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណ:កម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការ ចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណៈជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណ:** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ក្នុងនាមជាប្រធានព្រឹទ្ធសភា ជាមួយគណ:ប្រតិភូបរទេស និងអង្គទូតនានា

-ត្រៀមសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា (PIC) និង(IPU)

-ត្រៀមទទួលដំណើរទស្សនកិច្ចគណៈប្រតិភូអគ្គលេខាធិការព្រឹទ្ធសភាប៉ាគីស្ថាន(ខែធ្នូ ឆ្នាំ២០១៧) និងគណៈប្រតិភូសភាក្រុមប្រឹក្សានយោបាយប្រជាជនចិន (ខែសីហា ខែកញ្ញា ឆ្នាំ២០១៧ )

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-ចូលរួមប្រជុំ(IPU) នៅប្រទេសរុស្ស៊ី (ខែតុលា ឆ្នាំ២០១៧)

-ចូលរួមប្រជុំ (APF) និង(ASGPF) នៅប្រទេស Luxembourg

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា៖ SES, CIM, KAS, GIZ, MAX PLANCK FOUNDATION, UNESCO, JICA និង KOICA

-តាមដានគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

-បន្តបណ្តុះបណ្តាលការងារ (PBO) អ្នកស្រាវជ្រាវទូទៅ អ្នកស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិ និងការបោះពុម្ពសៀវភៅ Atlas

-សហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ និងការអនុវត្ត( MOU) សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវសភា ឥណ្ឌា និងប៉ាគីស្ថាន ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-បន្តរៀបចំជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈប្រើប្រាស់៖ អគារសាលប្រជុំពេញអង្គ អគារមូលនិធិខ្មែរអភិវឌ្ឍន៍ អគារការិយាល័យសមាជិកព្រឹទ្ធសភា និងក្នុងអគារថ្នាក់ដឹកនាំ ព្រមទាំងរៀបចំគូសគំនូសចំណតរថយន្ត និងស្លាកសញ្ញាបង្ហាញផ្លូវ (ផ្នែកខាងជើង)

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុង និងការកែសម្រួលរចនាសម្ព័ន្ធ

និងតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំអំពីលក្ខន្តិកៈសមាគមសង្គហៈមន្ត្រីរាជការក្រុមនីតិប្បញ្ញត្តិ

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមរៀបចំធ្វើសមាហរណកម្មមន្ត្រីចូលក្របខ័ណ្ឌថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលជាជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រកពពីកូរ៉េ ជប៉ុន ចិន អូស្ត្រាលី នូវែលហ្សេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី ថៃ និងប្រទេសផ្សេងៗទៀត

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកាតាមកម្មវិធីដាក់ស្ដែងក្នុងត្រីមាសទី៣ ឆ្នាំ២០១៧

-រៀបចំគម្រោងថវិកាតាមកម្មវិធីឆ្នាំ២០១៨ និងការការពារគម្រោងថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្រិតបច្ចេកទេស

-រៀបចំផែនការប្រតិបត្តិឆ្នាំ២០១៨ និងបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ១០ឆ្នាំ

-រៀបចំធ្វើរបាយការណ៍ចំណូល និងចំណាយថវិកាឆមាសទី១ ឆ្នាំ២០១៧

- រៀបចំរបាយការណ៍សកម្មភាពឆមាសទី១ និងទិសដៅឆមាសទី២

**III.សេចក្ដីសន្និដ្ឋាន**

ក្នុងខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ព្រមទាំងផ្ដល់សេវាលើមុខងារផ្សេងៗទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបានដោយរលូន ។ ការអភិវឌ្ឍស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានឆ្លុះបញ្ចាំងឲ្យឃើញ

អំពីលទ្ធផលវិជ្ជមាននៃការកៀរគរដៃគូឧបត្ថម្ភគាំទ្រជំនួយពីគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិ សំដៅអភិវឌ្ឍន៍ធនធានមធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែសម្បូរបែបទំនើប និងទាន់ការវិវត្តឥតឈប់ឈរបច្ចេកវិទ្យា រួមទាំងការរីកចម្រើនក្នុងតំបន់ និងពិភពលោក ។

ភ្នំពេញ, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧

**អគ្គលេខាធិការស្ដីទី**

ឡោក_ឆាយ